**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**រាជរដ្ឋាភិបាលកម្ពុជា**
**លេខ :** ២៣៤ អនក្រ.បក

# អនុក្រឹត្យ
# ស្តីពីការបង្កើតគណៈកម្មាធិការប្រតិបត្តិ និងអគ្គលេខាធិការដ្ឋាន ក្រុមប្រឹក្សាជាតិគាំពារសង្គម

## រាជរដ្ឋាភិបាលកម្ពុជា

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខនស/រកត/០៩១៣/៩០៣ចុះថ្ងៃទី២៤ខែកញ្ញាឆ្នាំ២០១៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១២១៣/១៣៩៣ ចុះថ្ងៃទី២១ ខែធ្នូ ឆ្នាំ២០១៣ ស្តីពីការកែសម្រួល និងបំពេញបន្ថែមសមាសភាពរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៤១៦/៣៦៨ ចុះថ្ងៃទី០៤ ខែមេសា ឆ្នាំ២០១៦ ស្តីពីការកែសម្រួល និងបំពេញបន្ថែមសមាសភាពរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ០២/នស/៩៤ ចុះថ្ងៃទី២០ខែកក្កដាឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខនស/រកម/០១៩៦/១០ចុះថ្ងៃទី២៤ខែមករាឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- បានឃើញព្រះរាជក្រមលេខនស/រកម/០១២១/០០៣ ចុះថ្ងៃទី១៦ ខែមករា ឆ្នាំ២០២១ ដែលប្រកាសឱ្យប្រើប្រាស់ច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃអាជ្ញាធរសេវាហិរញ្ញវត្ថុមិនមែនធនាគារ
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៦១៧/៤៨៨ ចុះថ្ងៃទី១៥ ខែមិថុនា ឆ្នាំ២០១៧ ស្តីពីការបង្កើតក្រុមប្រឹក្សាជាតិគាំពារសង្គម
- បានឃើញអនុក្រឹត្យលេខ ១១៣ អនក្រ.បក ចុះថ្ងៃទី១៤ ខែកក្កដា ឆ្នាំ២០២១ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅរបស់អង្គភាពក្រោមឱវាទរបស់អាជ្ញាធរសេវាហិរញ្ញវត្ថុមិនមែនធនាគារ
- បានឃើញអនុក្រឹត្យលេខ ២០ អនក្រ.បក ចុះថ្ងៃទី៣០ ខែមេសា ឆ្នាំ១៩៩៦ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃក្រសួង និងរដ្ឋលេខាធិការដ្ឋាន

- បានឃើញអនុក្រឹត្យលេខ ១១៤ អនក្រ.បក ចុះថ្ងៃទី០៧ ខែកញ្ញា ឆ្នាំ២០១៥ ស្តីពីការកំណត់រចនាសម្ព័ន្ធគ្រប់គ្រងនិងមុខតំណែងក្នុងរចនាសម្ព័ន្ធគ្រប់គ្រងនៃក្រសួង ស្ថាប័នថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ
- យោងតាមការស្នើសុំរបស់ប្រធានក្រុមប្រឹក្សាជាតិគាំពារសង្គម

## សម្រេច

## ជំពូកទី១

## បទប្បញ្ញត្តិទូទៅ

**មាត្រា ១** .-

អនុក្រឹត្យនេះ កំណត់អំពីការរៀបចំ និងការប្រព្រឹត្តទៅរបស់គណៈកម្មាធិការប្រតិបត្តិនៃក្រុមប្រឹក្សាជាតិគាំពារសង្គម សរសេរកាត់ថា **"គ.ប.ក.គ."** និងអគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាជាតិគាំពារសង្គម សរសេរកាត់ថា **"អ.ក.គ."** ដើម្បីគាំទ្រដល់ការបំពេញមុខងាររបស់ក្រុមប្រឹក្សាជាតិគាំពារសង្គម ឱ្យប្រព្រឹត្តទៅដោយរលូន និងមានប្រសិទ្ធភាពខ្ពស់។

## ជំពូកទី២

## គណៈកម្មាធិការប្រតិបត្តិនៃក្រុមប្រឹក្សាជាតិគាំពារសង្គម

## ផ្នែកទី១

## សមាសភាព

**មាត្រា ២** .-

**គ.ប.ក.គ.** មានសមាសភាព ដូចខាងក្រោម៖

| | | |
|---|---|---|
| ១- | រដ្ឋលេខាធិការក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ ១ រូប | ប្រធាន |
| ២- | រដ្ឋលេខាធិការ ឬអនុរដ្ឋលេខាធិការក្រសួងការងារ និង បណ្តុះបណ្តាលវិជ្ជាជីវៈ ១ រូប | អនុប្រធាន |
| ៣- | រដ្ឋលេខាធិការ ឬអនុរដ្ឋលេខាធិការក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា ១ រូប | អនុប្រធាន |
| ៤- | រដ្ឋលេខាធិការ ឬអនុរដ្ឋលេខាធិការក្រសួងសុខាភិបាល ១ រូប | អនុប្រធាន |
| ៥- | អគ្គលេខាធិការនៃក្រុមប្រឹក្សាស្តារអភិវឌ្ឍន៍វិស័យកសិកម្មនិងជនបទ | អនុប្រធាន |
| ៦- | អគ្គលេខាធិការក្រុមប្រឹក្សាជាតិគាំពារសង្គម | អនុប្រធានប្រចាំការ |
| ៧- | តំណាងទីស្តីការគណៈរដ្ឋមន្ត្រី ១ រូប | សមាជិក |
| ៨- | តំណាងក្រសួងមហាផ្ទៃ ១ រូប | សមាជិក |
| ៩- | តំណាងក្រសួងការពារជាតិ ១ រូប | សមាជិក |
| ១០- | តំណាងក្រសួងផែនការ ១ រូប | សមាជិក |
| ១១- | តំណាងក្រសួងយុត្តិធម៌ ១ រូប | សមាជិក |
| ១២- | តំណាងក្រសួងកិច្ចការនារី ១ រូប | សមាជិក |

១៣- តំណាងក្រសួងអប់រំ យុវជន និងកីឡា ១ រូប សមាជិក

១៤- តំណាងក្រសួងមុខងារសាធារណៈ ១ រូប សមាជិក

១៥- តំណាងគណៈកម្មាការជាតិគ្រប់គ្រងគ្រោះមហន្តរាយ ១ រូប សមាជិក

១៦- អគ្គនាយកនៃអគ្គនាយកដ្ឋានពន្ធដារនៃក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ សមាជិក

១៧- អគ្គនាយកនៃអគ្គនាយកដ្ឋានគោលនយោបាយនៃក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ សមាជិក

១៨- អគ្គនាយកនៃអគ្គនាយកដ្ឋានថវិកានៃក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ សមាជិក។

**គ.ប.ក.គ.** អាចមានសមាសភាពបន្ថែមតាមការចាំបាច់។ សមាសភាពជាក់ស្តែងនៃ **គ.ប.ក.គ.** ត្រូវកំណត់ដោយសេចក្តីសម្រេចរបស់រាជរដ្ឋាភិបាល។

## ជំពូកទី២
## តួនាទី និងភារកិច្ច

**មាត្រា ៣** .-

**គ.ប.ក.គ.** ជាយន្តការសម្របសម្រួលកម្រិតគោលនយោបាយ និងកម្រិតបច្ចេកទេស សម្រាប់គាំទ្រាល់ការបំពេញមុខងារ និងភារកិច្ចរបស់ក្រុមប្រឹក្សាជាតិគាំពារសង្គម ដែលមានចែងក្នុងមាត្រា៣នៃព្រះរាជក្រឹត្យស្តីពីការបង្កើតក្រុមប្រឹក្សាជាតិគាំពារសង្គម។

**គ.ប.ក.គ.** មានភារកិច្ចសម្របសម្រួល តាមដាន និងត្រួតពិនិត្យការអនុវត្តគោលនយោបាយ និងផែនការយុទ្ធសាស្ត្រនានាពាក់ព័ន្ធនឹងការងារគាំពារសង្គមដើម្បីរាយការណ៍ និងផ្តល់យោបល់ជូនក្រុមប្រឹក្សាជាតិគាំពារសង្គម។

**គ.ប.ក.គ.** អាចស្នើសុំប្រធានក្រុមប្រឹក្សាជាតិគាំពារសង្គម កោះប្រជុំក្រុមប្រឹក្សាជាតិគាំពារសង្គមតាមការចាំបាច់។

**មាត្រា ៤** .-

**គ.ប.ក.គ.** អាចស្នើសុំក្រុមប្រឹក្សាជាតិគាំពារសង្គម ដើម្បីបង្កើតអនុគណៈកម្មាធិការ ឬក្រុមការងារបច្ចេកទេសស្របតាមតម្រូវការនៃការអភិវឌ្ឍប្រព័ន្ធគាំពារសង្គម។

អនុគណៈកម្មាធិការ ក្រុមការងារបច្ចេកទេស និងក្រសួង-ស្ថាប័នពាក់ព័ន្ធដែលមានសកម្មភាព ឬប្រតិបត្តិការគាំពារសង្គម ត្រូវផ្តល់របាយការណ៍អំពីការបំពេញការងាររបស់ខ្លួនជូន **គ.ប.ក.គ.** ជាប្រចាំ។

បែបបទ និងទម្រង់នៃរបាយការណ៍ ត្រូវកំណត់ដោយសេចក្តីណែនាំរបស់ក្រុមប្រឹក្សាជាតិគាំពារសង្គម។

**មាត្រា ៥** .-

**គ.ប.ក.គ.** មានភារកិច្ចសម្របសម្រួល និងជាសេនាធិការរបស់ក្រុមប្រឹក្សាជាតិគាំពារសង្គម ដើម្បីកៀរគរធនធានហិរញ្ញវត្ថុ និងកសាងភាពជាដៃគូលើកិច្ចសហប្រតិបត្តិការជាតិ និងអន្តរជាតិក្នុងកិច្ចការគាំពារសង្គម។

## ផ្នែកទី៣
## ការប្រជុំនៃគណៈកម្មាធិការប្រតិបត្តិ

**មាត្រា ៦** . -

អនុប្រធាន និងសមាជិកនៃ **គ.ប.ក.គ.** ត្រូវចូលរួមប្រជុំតាមការអញ្ជើញរបស់ប្រធាន ឬត្រូវចាត់តំណាងដែលមានសិទ្ធិសម្រេចឱ្យចូលរួមប្រជុំជំនួស ក្នុងករណីអវត្តមាន។

**គ.ប.ក.គ.** អាចអញ្ជើញប្រធានអនុគណៈកម្មាធិការ ប្រធានក្រុមការងារបច្ចេកទេស ឬតំណាងក្រសួង-ស្ថាប័នពាក់ព័ន្ធនានា តំណាងដៃគូអភិវឌ្ឍន៍ តំណាងវិស័យឯកជន និងតំណាងសង្គមស៊ីវិល ដើម្បីពិភាក្សាការងារក្នុងគោលដៅជំរុញវឌ្ឍនភាពនៃការអភិវឌ្ឍប្រព័ន្ធគាំពារសង្គម តាមការចាំបាច់។

**មាត្រា ៧**. -

ប្រធាន **គ.ប.ក.គ.** ក្នុងនាមជាសេនាធិការដឹកនាំ ត្រូវចូលរួមកិច្ចប្រជុំក្រុមប្រឹក្សាជាតិគាំពារសង្គមក្នុងនាមជាអ្នកផ្តល់យោបល់។ ក្នុងករណីអវត្តមាន ប្រធាន **គ.ប.ក.គ.** ត្រូវផ្ទេរសិទ្ធិជូនអនុប្រធានដើម្បីចូលរួមប្រជុំជំនួស។

## ជំពូកទី៣
## អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាជាតិគាំពារសង្គម

## ផ្នែកទី១
## ការបង្កើតអគ្គលេខាធិការដ្ឋាន

**មាត្រា ៨**. -

ត្រូវបានបង្កើតអគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាជាតិគាំពារសង្គម ជាសេនាធិការបច្ចេកទេសគាំទ្រការប្រព្រឹត្តទៅរបស់ក្រុមប្រឹក្សាជាតិគាំពារសង្គម និងគណៈកម្មាធិការប្រតិបត្តិ ដូចមានចែងក្នុងមាត្រា ៥ នៃព្រះរាជក្រឹត្យស្តីពីការបង្កើតក្រុមប្រឹក្សាជាតិគាំពារសង្គម។

អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាជាតិគាំពារសង្គម បំពេញមុខងារបន្ថែមជានិយ័តករសន្តិសុខសង្គម ដូចមានចែងក្នុងមាត្រា១៨ នៃច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃអាជ្ញាធរសេវាហិរញ្ញវត្ថុមិនមែនធនាគារ។

## ផ្នែកទី២
## រចនាសម្ព័ន្ធ មុខងារ និងភារកិច្ច

**មាត្រា ៩**. -

**អ.ក.គ.** មានរចនាសម្ព័ន្ធ មុខងារ និងភារកិច្ច ដូចខាងក្រោម៖

- **នាយកដ្ឋានគោលនយោបាយ** មានមុខងារ និងភារកិច្ច ជួយ អ.ក.គ. លើការងាររៀបចំ ពិនិត្យ និងផ្តល់យោបល់លើគោលនយោបាយគាំពារសង្គមជារួម ការងាររៀបចំបង្កើត និងដាក់ឱ្យដំណើរការរបបសន្តិសុខសង្គម ឬកម្មវិធីជាតិជំនួយសង្គមនានា

- **នាយកដ្ឋានគាំទ្រប្រតិបត្តិការ** មានមុខងារ និងភារកិច្ច ជួយ អ.ក.គ. លើការងារគ្រប់គ្រងមូលនិធិហិរញ្ញប្បទានគាំពារសង្គម ការងារតាមដាន និងដោះស្រាយវិវាទក្នុងការអនុវត្តកម្មវិធីជាតិជំនួយសង្គម និងការងារបញ្ជ្រាបការយល់ដឹង ទំនាក់ទំនង និងការផ្សព្វផ្សាយ
- **នាយកដ្ឋានកិច្ចការរដ្ឋបាល និងឌីជីថល** មានមុខងារ និងភារកិច្ច ជួយ អ.ក.គ. លើការងាររដ្ឋបាល និងការគ្រប់គ្រងបុគ្គលិក ការងារគ្រប់គ្រងថវិកាកម្មវិធី និងគម្រោងអភិវឌ្ឍន៍ស្ថាប័ន និងការងារអភិវឌ្ឍ និងអនុវត្តថ្នាលឌីជីថល
- **នាយកដ្ឋានត្រួតពិនិត្យ** មានមុខងារ និងភារកិច្ច ជួយ អ.ក.គ. ក្នុងមុខងារជានិយ័តករសន្តិសុខសង្គម លើការងាររៀបចំបទប្បញ្ញត្តិពាក់ព័ន្ធនឹងនិយ័តកម្មប្រព័ន្ធសន្តិសុខសង្គម និងការងារត្រួតពិនិត្យប្រតិបត្តិការសន្តិសុខសង្គម
- **នាយកដ្ឋានផ្សះផ្សាវិវាទ និងការពារអ្នកទទួលផល** មានមុខងារ និងភារកិច្ច ជួយ អ.ក.គ. ក្នុងមុខងារជានិយ័តករសន្តិសុខសង្គម លើការងារការពារអ្នកទទួលផល ការងារទទួលពាក្យបណ្តឹង និងការងារដោះស្រាយវិវាទ ក្នុងប្រព័ន្ធសន្តិសុខសង្គម
- **នាយកដ្ឋានកិច្ចការទូទៅ** មានមុខងារ និងភារកិច្ច ជួយ អ.ក.គ. ក្នុងមុខងារជានិយ័តករសន្តិសុខសង្គម លើការងារថវិកា និងការគ្រប់គ្រងបុគ្គលិក ការងារគាំទ្រប្រតិបត្តិការពាក់ព័ន្ធនឹងប្រព័ន្ធព័ត៌មានវិទ្យា និងការងារសម្របសម្រួលក្នុងក្របខណ្ឌអាជ្ញាធរសេវាហិរញ្ញវត្ថុមិនមែនធនាគារ និង
- **អង្គភាពស្រាវជ្រាវ** មានមុខងារ និងភារកិច្ច ជួយ អ.ក.គ. លើការងារសិក្សាស្រាវជ្រាវទូទៅ។

អង្គភាព និងនាយកដ្ឋាននីមួយៗ ដឹកនាំដោយប្រធាន ១ រូប និងមានអនុប្រធានមួយចំនួនអនុលោមតាមបទដ្ឋានគតិយុត្តជាធរមាន។

អង្គការលេខរបស់អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាជាតិគាំពារសង្គម ត្រូវបានកំណត់ក្នុងឧបសម្ព័ន្ធនៃអនុក្រឹត្យនេះ។

ការរៀបចំ និង ការប្រព្រឹត្តទៅនៃអគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាជាតិគាំពារសង្គម ត្រូវកំណត់ដោយសេចក្តីសម្រេចរបស់ប្រធានក្រុមប្រឹក្សាជាតិគាំពារសង្គម។

## ផ្នែកទី៣
## ថ្នាក់ដឹកនាំ មន្ត្រី និងបុគ្គលិក

**មាត្រា ១០.** -

អគ្គលេខាធិការដ្ឋាន ត្រូវដឹកនាំដោយអគ្គលេខាធិការ ១ រូប និងមានអគ្គលេខាធិការរងមួយចំនួនអនុលោមតាមបទប្បញ្ញត្តិជាធរមាន។

អគ្គលេខាធិការ ត្រូវបានតែងតាំង និងបញ្ចប់ភារកិច្ចដោយព្រះរាជក្រឹត្យ តាមការស្នើសុំរបស់ប្រធានក្រុមប្រឹក្សាជាតិគាំពារសង្គម។

**មាត្រា ១១**. -

អគ្គលេខាធិការរង ត្រូវបានតែងតាំង និងបញ្ចប់ភារកិច្ចដោយអនុក្រឹត្យ តាមការស្នើសុំរបស់ប្រធានក្រុមប្រឹក្សាជាតិគាំពារសង្គម។ អគ្គលេខាធិការរង អាចត្រូវបានតែងតាំងជាអគ្គនាយករងនៃនិយ័តករសន្តិសុខសង្គម តាមការចាំបាច់។

**មាត្រា ១២**.-

អ.ក.គ. អាចជ្រើសរើសមន្ត្រីរាជការមុខងារសាធារណៈ ពីក្រសួង-ស្ថាប័ននានា និងពីក្នុងចំណោមសិស្ស និស្សិតមកបម្រើការងារនៅ អ.ក.គ. ក្នុងក្របខណ្ឌក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ ស្របតាមនីតិវិធីជាធរមាន។

**មាត្រា ១៣**.-

អ.ក.គ. អាចជ្រើសរើសបុគ្គលិកជាប់កិច្ចសន្យា និងទីប្រឹក្សាជាអ្នកជំនាញការជាតិ ឬអន្តរជាតិ មកបម្រើការងារ ដោយមានការឯកភាពពីប្រធានក្រុមប្រឹក្សាជាតិគាំពារសង្គម អនុលោមតាមបែបបទ និងនីតិវិធីជាធរមាន។

## ផ្នែកទី៤
## ថវិកា

**មាត្រា ១៤**. -

**អ.ក.គ** មានកញ្ចប់ថវិកាដោយឡែកសម្រាប់គាំទ្រកិច្ចដំណើរការរបស់ក្រុមប្រឹក្សាជាតិគាំពារសង្គម **គ.ប.ក.គ** និង **អ.ក.គ** ផ្ទាល់។ កញ្ចប់ថវិការបស់ **អ.ក.គ** អាចមានប្រភពមកពី៖

- ថវិការដ្ឋដែលស្ថិតនៅក្រោមកញ្ចប់ថវិការបស់ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ និង
- ប្រភពស្របច្បាប់ផ្សេងៗទៀត។

ថវិការបស់ **អ.ក.គ** ត្រូវសម្រេចដោយរដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ តាមការស្នើសុំរបស់អគ្គលេខាធិការ តាមរយៈប្រធាន គ.ប.ក.គ។

## ផ្នែកទី៥
## សវនកម្ម

**មាត្រា ១៥**. -

**អ.ក.គ** ត្រូវស្ថិតក្រោមការធ្វើអធិការកិច្ច និងសវនកម្ម ស្របតាមច្បាប់ជាធរមាន។

## ជំពូកទី៤
## អវសានប្បញ្ញត្តិ

**មាត្រា ១៦**. -

អនុក្រឹត្យលេខ០៣ អនក្រ.បក ចុះថ្ងៃទី៨ ខែមករា ឆ្នាំ២០១៨ ស្តីពីការបង្កើតគណៈកម្មាធិការប្រតិបត្តិ និងអគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាជាតិគាំពារសង្គម និងអនុក្រឹត្យលេខ១៤៣ ចុះថ្ងៃទី១៩ ខែសីហា ឆ្នាំ២០២១ ស្តីពីការកែសម្រួលអនុក្រឹត្យលេខ០៣ អនក្រ.បក និងបទប្បញ្ញត្តិទាំងឡាយណាដែលផ្ទុយនឹងអនុក្រឹត្យទាំងពីរនេះ ត្រូវទុកជានិរាករណ៍។

**មាត្រា ១៧.-**

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ រដ្ឋមន្ត្រីគ្រប់ក្រសួង និងប្រធានគ្រប់ស្ថាប័នពាក់ព័ន្ធ ត្រូវទទួលបន្ទុកអនុវត្តអនុក្រឹត្យនេះ ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

ថ្ងៃ ចន្ទ ៦ រោច ខែទុតិយាសាឍ ឆ្នាំថោះ បញ្ចស័ក ព.ស ២៥៦៧

រាជធានីភ្នំពេញ ថ្ងៃទី ៧ ខែសីហា ឆ្នាំ២០២៣

**នាយករដ្ឋមន្ត្រី**

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

បានយកសេចក្តីគោរពជម្រាបជូន
សម្តេចអគ្គមហាសេនាបតីតេជោនាយករដ្ឋមន្ត្រីសូមហត្ថលេខា

**ឧបនាយករដ្ឋមន្ត្រី**
**រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ**
**និងជាប្រធានក្រុមប្រឹក្សាជាតិគាំពារសង្គម**

**អគ្គបណ្ឌិតសភាចារ្យ អូន ព័ន្ធមុនីរ័ត្ន**

**កន្លែងទទួល៖**

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- ខុទ្ទកាល័យសម្តេចអគ្គមហាសេនាបតីតេជោនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យសម្តេច ឯកឧត្តម ឧបនាយករដ្ឋមន្ត្រី
- ដូចមាត្រា១៧
- រាជកិច្ច
- ឯកសារ កាលប្បវត្តិ

ឧបសម្ព័ន្ធនៃអនុក្រឹត្យលេខ...២៣៤អនក្រ.បក...ចុះថ្ងៃទី...២៧.....ខែ...សីហា.....ឆ្នាំ២០២៣

## អង្គការលេខរបស់

## អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាជាតិគាំពារសង្គម (អ.ក.គ.)

